ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅប្រទេសម៉ាឡេស៊ី និងចិន ជួយសង្គ្រោះពលរដ្ឋខ្មែរចំនួន៥នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៤នាក់** ដូចខាងក្រោម៖

- ស្ត្រីឈ្មោះ **យ.ស.ល** អាយុ២៣ឆ្នាំ មកពីស្រុកចំការលើ ខេត្តកំពង់ចាម រួមនឹងកូនប្រុសអាយុ៣ឆ្នាំ ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅម៉ាឡេស៊ីដោយខុសច្បាប់ ដោយធ្វើដំណើរតាមរថយន្តកាត់តាមព្រំដែនថៃ ទៅធ្វើជាអ្នកសុំទាន ពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាងបានស្នើសុំស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានចេញថ្លៃបង់ពិន័យជូនការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី និងឧបត្ថម្ភសំបុត្រយន្តហោះជូនអ្នកទាំងពីរ ដើម្បីបានត្រឡប់មកកម្ពុជា។

- ពលការិនី **ជ.ស.ខ** អាយុ៣៥ឆ្នាំ មកពីស្រុកតំបែរ ខេត្តកំពង់ចាម ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅធ្វើការជាអ្នកបោសសំអាតនៅម៉ាឡេស៊ី ពីខែសីហាឆ្នាំ២០១៦ ដោយធ្វើដំណើរតាមរថយន្តកាត់តាមព្រំដែនថៃ។ ដោយពុំអាចទ្រាំនឹងការងារលំបាក នាងបានស្នើស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

- ពលការិនី **ស.ន** អាយុ៣៧ឆ្នាំ មកពីស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត នៅខែវិច្ឆិកា ឆ្នាំ២០១៦ តាមការណែនាំរបស់មេខ្យល់។ ដោយពុំអាចទ្រាំនឹងការងារលំបាក ពលការិនីបានទៅស្ថានទូតនៅ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ព្រមទាំងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ជូនអ្នកទាំង៤ មុនពេលរៀបចំមាតុភូមិនិវត្តន៍របស់ពួកគេ។

ពលរដ្ឋខ្មែរទាំង៤នាក់ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** ថ្ងៃទី**០១** ខែ**មីនា** ឆ្នាំ**២០១៧** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

២. ឆ្លើយតបនឹងការស្នើសុំពីម្តាយរបស់ស្ត្រីរងគ្រោះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានណែនាំអោយស្ថានឯកអគ្គរាជទូតនិងស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសចិន អន្តរាគមជួយសង្គ្រោះនិងរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរម្នាក់ឈ្មោះ **ហ.ស.ទ** អាយុ២៨ឆ្នាំ ដែលចាញ់បោកមេខ្យល់ទៅរៀបការជាមួយបុរសជនជាតិចិន ហើយមានបំណងវិលត្រឡប់មកកម្ពុជាវិញ។

យោងតាមរបាយការណ៍របស់ស្ថានទូត ស្ត្រីរងគ្រោះ មកពីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ត្រូវបានមេខ្យល់បញ្ឆោះបញ្ចូលនាំទៅប្រទេសចិន និងចុះអេតាស៊ីវិលជាមួយបុរសចិនម្នាក់ដែលមានសតិមិនគ្រប់ ក្នុងអំឡុងខែមេសា ឆ្នាំ២០១៤ នៅទីក្រុង Nanping នៃខេត្ត Fujian ប៉ុន្តែបានលែងលះគ្នាវិញ ក្នុងខែសីហា ឆ្នាំ២០១៤ ។ បន្ទាប់មក នាងបានចុះអេតាស៊ីវិលជាមួយបុរសចិនម្នាក់ទៀតនៅខែកញ្ញា ឆ្នាំ២០១៤ ក្នុងទីក្រុងNanping ដដែល។ ២ខែក្រោយមក នាងត្រូវបានគេបង្ខំអោយទៅរស់នៅជាមួយបុរសចិនផ្សេងទៀត នៅទីក្រុង Hanzhou នៃខេត្ត Zhejian ។ នាងមិនទទួលរងអំពើហឹង្សាពីប្តីនោះទេ តែធ្លាប់ឈ្លោះទាស់ទែងគ្នាជារឿយៗ។

ស្ថានទូតកម្ពុជាបានស្នើសុំការជួយអន្តរាគមន៍ពីក្រសួងការបរទេសចិនលើករណីនេះ ហើយនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ នគរបាលចិនបានទៅដល់ផ្ទះនារីរងគ្រោះនៅទីក្រុងHanzhou និងនាំនាងទៅប៉ុស្ដិ៍នគរបាល ដើម្បីសួរនាំបន្ត។ នៅថ្ងៃទី១៩ ខែកុម្ភៈ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ បានទទួលនាងពីប៉ុស្ដិ៍នគរបាលHanzhou នាំទៅទីក្រុងសៀងហៃ ដើម្បីបន្តរៀបចំមាតុភូមិនិវត្តន៍មកកម្ពុជា។

ស្ត្រីរងគ្រោះ **ហ.ស.ទ** បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៦** ខែ**កុម្ភៈ** ឆ្នាំ**២០១៧** វេលាម៉ោង**២៣:១៥** នាទី តាមជើងយន្តហោះ **MU 759** ៕

ភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ